ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២០០/១៣-ស៊ុន ខេង ហ្គាមេន (ខេមបូឌា)

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា)**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៤ ភូមិស្លា ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១២ ៦២៦ ៨៦៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | | |
|---|---|---|
| ១- | លោក ហំ ភា | មេធាវី |
| ២- | លោក វីម វីរៈ | ជំនួយការមេធាវី |
| ៣- | លោក ឈុន សៀ | រដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ក/ឈ្មោះ ៖ -**សហព័ន្ធសហជីពអំណាចកម្មករខ្មែរ**

-**សហជីពអំណាចកម្មករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា)**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៤ ភូមិស្លា ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០៩២ ៩៥ ៧៤ ៧២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖ **អវត្តមាន**

ខ/ឈ្មោះ ៖ **-សហព័ន្ធសហជីពសេរីពលករខ្មែរ**

**-សហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា)**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៤ ភូមិស្លា ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១២ ៦៣៨ ១៩១ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ប៊ុត ធឿន | មន្ត្រីសហព័ន្ធសហជីពសេរីពលករខ្មែរ |
| ២- លោក មាស សំណាង | មន្ត្រីសហព័ន្ធសហជីពសេរីពលករខ្មែរ |
| ៣- លោក ព្រំ កុសល | លេខាធិការសហព័ន្ធសហជីពសេរីពលករខ្មែរ |
| ៤- លោក សុខ សុខណា | ប្រធានសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |
| ៥- លោក ឌឹម សួនី | លេខាធិការសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |
| ៦- កញ្ញា ហៀង ថាវី | សមាជិកសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |
| ៧- កញ្ញា សំ វណ្ណា | សមាជិកសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |
| ៨- កញ្ញា ញឹល ស៊ីថា | សមាជិកសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |
| ៩- កញ្ញា យួន រីម | សមាជិកសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |
| ១០- កញ្ញា ងីម ដួន | សមាជិកសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |
| ១១- កញ្ញា សួច ស្រីម៉ៅ | សមាជិកសហជីពសេរីពលករខ្មែរប្រចាំក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុននៅពេលកម្មករ កម្មការិនីឈឺមានសំបុត្រពេទ្យត្រឹមត្រូវ (ពេទ្យស្រុក) ក្រុមហ៊ុនមិនត្រូវកាត់លុយផ្សេងៗរបស់កម្មករ កម្មការិនីឡើយ។

២- សុំឱ្យក្រុមហ៊ុនបើកលុយថ្លៃបាយថ្ងៃត្រង់របស់កម្មករ កម្មការិនីឱ្យអស់។

៣- សុំឱ្យក្រុមហ៊ុនផ្តល់លុយថ្លៃទឹកដោះគោ សម្រាប់កម្មការិនីសម្រាលកូនរួច។

៤- សុំឱ្យក្រុមហ៊ុនបើកលុយជូនកម្មករ កម្មការិនីនៅខែ ៩ មុនរដូវភ្ជុំបិណ្ឌ។

៥- សុំឱ្យក្រុមហ៊ុនបែងចែកការងារឱ្យបានច្បាស់លាស់ចំពោះ អ្នកអនាម័យ និងកម្មករ។

៦- សុំឱ្យក្រុមហ៊ុនផ្តល់លុយជំនាញ និងបច្ចេកទេសកម្មករ កម្មការិនីដូចជា ៖ មេកន្ត្រៃ ចេះម៉ាស៊ីនពីរ ទៅបីម៉ាស៊ីន។

៧- នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើ ក្រុមហ៊ុនមិនត្រូវកាត់លុយប្រចាំឆ្នាំឡើយ។

៨- នៅពេលកម្មករធ្វើកូដកម្ម សូមក្រុមហ៊ុនមិនត្រូវកាត់លុយកម្មករ។

៩- ស្នើសុំក្រុមហ៊ុនស្កេនមេដៃ មួយថ្ងៃពីរដង ពេលម៉ោងចូលធ្វើការ (ព្រឹក) ពេលចេញពីធ្វើការល្ងាច។

១០- ស្នើសុំក្រុមហ៊ុនផ្តល់លុយព្រីមចំនួន ១៥ ដុល្លារ ឱ្យកម្មករ។

១១- ស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ធ្វើដំណើរចំនួន ១៥ ដុល្លារ។

១២- សុំឱ្យក្រុមហ៊ុនបើកប្រាក់ខែមុនថ្ងៃទី០៨។

១៣- សុំឱ្យក្រុមហ៊ុន កុំរើសអើងសហជីព។

១៤- ក្រុមហ៊ុនមិនត្រូវបញ្ឈប់កម្មករក្រៅពីកំហុសធ្ងន់។

១៥- សូមឱ្យក្រុមហ៊ុនមានច្បាប់ ពីរម៉ោងក្នុងមួយថ្ងៃ សម្រាប់កម្មករមានធុរៈ។

១៦- សូមកុំឱ្យក្រុមហ៊ុនដាក់ជើងកាង នៅក្នុងរោងចក្រគំរាមកម្មករ និងសហជីព។

១៧- សូមឱ្យលោកអគ្គនាយកផ្លាស់ប្តូរអ្នកគ្រប់គ្រងរដ្ឋបាលចេញ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជាមួយគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១២៣១/១៣ កប/កសួ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣។

THE ARBITRATION COUNCIL

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ បានធ្វើការផ្សះផ្សាវិវាទការងាររួមរបស់សហព័ន្ធសហជីពអំណាចកម្មករខ្មែរ និងសហព័ន្ធសហជីពសេរីពលករខ្មែរ (តាមពាក្យបណ្តឹង) ចំនួន ១៩ ចំណុច ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជា ចំនួន ១៩ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ១២៣១/១៣ កប/កស្គ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ១៩ ចំណុចនេះ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១៤៖០០ នាទី រសៀល។ ភាគីនិយោជកមានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចំណែកភាគីកម្មករនិយោជិត គឺមានតែសហព័ន្ធសហជីពសេរីពលករខ្មែរ ដែលមានវត្តមាន រីឯសហព័ន្ធសហជីពអំណាចកម្មករខ្មែរ មិនមានវត្តមាននៅក្នុងសវនាការទេ ហើយក៏មិនបានជូនដំណឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលអំពីការមិនបានចូលរួមនេះដែរ។

នៅថ្ងៃសវនាការ នៅពេលក្រុមប្រឹក្សាអាជ្ញាកណ្តាលកំពុងដំណើរការអាជ្ញាកណ្តាល ភាគីកម្មករនិយោជិតបានដើរចេញពីបន្ទប់សវនាការម្តងម្នាក់ៗ នៅវេលាម៉ោង ១៧៖១០ នាទី ដោយមិនមានការជូនដំណឹង ឬសុំការអនុញ្ញាតពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីនិយោជក។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម ៖

## តស៊ូតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់នាយកគ្រប់គ្រងក្រុមហ៊ុន SON KENG GARMENT (CAMBODIA) CO.,LTD ប្រគល់សិទ្ធិជូនមេធាវី ហំ ភា ជាតំណាងឱ្យក្រុមហ៊ុន SON KENG GARMENT (CAMBODIA) CO.,LTD នៅក្នុងសំណុំរឿងលេខ ២០០/១៣ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣។

២- កំណត់ហេតុកិច្ចព្រមព្រៀងរវាងនាយកក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន និងសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ, សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ, សហព័ន្ធសហជីពការងារកម្មករកម្ពុជា, សហព័ន្ធសហជីពការងារដើម្បីកម្ពុជា ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣។

៣- សេចក្តីជូនដំណឹងស្តីពីលទ្ធផលអង្គប្រជុំថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ៣៖០០ រសៀល នៅរោងចក្រ ស៊ុន ខេង ហ្គាមេន។

៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ចុះទិដ្ឋការលេខ ៨៣៥/១៣ កប/កស្ត ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣។

៥- លក្ខន្តិកៈក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២។

៦- ប័ណ្ណប៉ាតង់លេខ DLT.038969.2013 ក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣។

៧- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ៥៥៦៩ ពណ.ចបព របស់ក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២។

៨- កំណត់ហេតុអង្គប្រជុំរវាងតំណាងក្រុមហ៊ុន ស៊ុន ខេង និងតំណាងសហជីព កម្មករនិយោជិតក្រុមហ៊ុន ស៊ុន ខេង ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣។

៩- កំណត់ហេតុអង្គប្រជុំរវាងតំណាងក្រុមហ៊ុន ស៊ុខ ខេង និងតំណាងកម្មករនិយោជិតក្រុមហ៊ុន ស៊ុន ខេង ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន លេខ ១២៣១/១៣ កប/កស្ត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១០១៣ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១០១៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣។

៣- សេចក្តីបញ្ជាក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៣៦/១៣ កបអ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញលិខិតអញ្ជើញលេខ ១០១៤ កប/អក/វក/លកអ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ទៅសហព័ន្ធសហជីពអំណាចកម្មករខ្មែរ, សហព័ន្ធសហជីពសេរីពលករខ្មែរ និងលោក លោកស្រី និងអ្នកតំណាង កម្មករនិយោជិតនៃក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ដែលជាភាគីកម្មករនិយោជិត (ភាគីដើមបណ្តឹង) ដើម្បីមកចូលរួមសវនាការអាជ្ញាកណ្តាល ដែលមានព័ត៌មានដូចតទៅ ៖
    - កាលបរិច្ឆេទនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ០០ នាទី និង
    - ទីកន្លែងនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២, ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ និង
    - ទូរស័ព្ទ/ទូរសារលេខ ០២៣ ៨៨១ ៨២៤ ។
- លោក សុខ សុខហួត ដែលជាហិរញ្ញិកសហព័ន្ធសហជីពអំណាចកម្មករខ្មែរ បានទទួលលិខិតអញ្ជើញនេះ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ០៨ និង ៤៤ នាទី ដោយបានចុះហត្ថលេខាបញ្ជាក់ការទទួលផងដែរ ។
- នៅក្នុងករណីនេះ សហព័ន្ធសហជីពអំណាចកម្មករខ្មែរ និងសហព័ន្ធសហជីពសេរីពលករខ្មែរ គឺជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ។ នៅថ្ងៃសវនាការ សហព័ន្ធសហជីពអំណាចកម្មករខ្មែរ មិនមានវត្តមាននៅក្នុងសវនការទេ ហើយក៏មិនបានជូនដំណឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលអំពីការមិនបានចូលរួមនេះដែរ ។
- នៅថ្ងៃសវនាការ មន្ត្រីសហព័ន្ធសហជីពសេរីពលករខ្មែរ ចំនួន ០៣ នាក់ និងកម្មករនិយោជិតចំនួន ០៨ នាក់ មានវត្តមាននៅក្នុងសវនាការ ។
- យោងតាមរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ចំណុចវិវាទទាំងអស់របស់ភាគីកម្មករនិយោជិតមាន ចំនួន ១៩ ចំណុច ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើសវនាការទៅលើចំណុចវិវាទ ចំនួន ០៩ (ចំណុចវិវាទទី០៩ ដល់ទី១៧) របស់សហព័ន្ធសហជីពសេរីពលករខ្មែរ ដោយមិនធ្វើសវនាការទៅលើចំណុចវិវាទរបស់សហព័ន្ធសហជីពអំណាចកម្មករខ្មែរទេ ។
- ក្នុងចំណោមចំណុចវិវាទទាំង ០៩ ភាគីកម្មករនិយោជិត និងភាគីនិយោជកបានព្រមព្រៀងគ្នាទៅលើចំណុចវិវាទចំនួន ៦ ចំណុច (ចំណុចវិវាទទី១២, ទី១៣, ទី១៤, ទី១៥, ទី១៦ និងទី១៧) ។ ចំណែកចំណុចវិវាទទី ០៩, ទី១០ និងទី១១ ភាគីទាំងពីរមិនបានព្រមព្រៀងជាមួយគ្នាទេ ។
- ប៉ុន្តែ ចំណុចព្រមព្រៀងទាំង ៦ ចំណុចនេះ មិនទាន់បានចុះហត្ថលេខាទេ ហើយចំណុចដែលនៅសល់ក៏មិនទាន់បានសវនាការលើអង្គសេចក្តីចប់ដែរ ព្រោះភាគីកម្មនិយោជិតបានដើរចេញពីសវនាការ ដោយគ្មានការជូនដំណឹង បន្ទាប់ពីការពិភាក្សាលើការទាមទារឱ្យនិយោជករក្សាប្រាក់ឈ្នួលឱ្យកម្មករ នៅក្នុងអំឡុងពេលកូដកម្មមិនបានជោគជ័យ ពីព្រោះតែភាគីនិយោជកបានឆ្លើយថា និយោជកសុំពេលពិចារណាសិន មុននឹង

ឆ្លើយតបវិញ *(ចំណុចវិវាទដែលភាគីកម្មករនិយោជិតបានសួរនេះ មិនមាននៅក្នុងរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ ទេ)* ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ នៅពេលដែលភាគីកម្មករនិយោជិត បានដើរចេញពីបន្ទប់សវនាការ មុនពេលការដំណើរការអាជ្ញាកណ្តាលត្រូវបានបញ្ចប់ ឬត្រូវបញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងនេះ?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និង ព័ត៌មានចាំបាច់ផ្សេងៗទៀត"*។

ប្រការ ២០ នៃប្រកាសដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"*

ប្រការ ២១ នៃប្រកាសដដែលនេះ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់ "*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

តាមរយៈប្រការ ១៨, ប្រការ ២០ និងប្រការ ២១ នៃប្រកាសលេខ ០៩៩ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ដែលបានលើកឡើងខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានកាតព្វកិច្ចអញ្ជើញភាគីវិវាទ មកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការសម្រេចសេចក្តី។ ភាគីនៃវិវាទមានកាតព្វកិច្ចត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ។ ក្នុងករណីដែលភាគីណាមួយមិនបានចូលរួមតាមការអញ្ជើញនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការអាជ្ញាកណ្តាល ដោយអវត្តមានភាគី ឬបញ្ចប់ដំណើរការអាជ្ញាកណ្តាលបាន។ ការសម្រេចជ្រើសរើសជម្រើសណាមួយនៃជម្រើសទាំងពីរនេះ ត្រូវបំពេញនូវលក្ខខណ្ឌបី គឺលក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញ

ត្រឹមត្រូវ, លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

***<u>លក្ខខណ្ឌទី ០១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ</u>***

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញលិខិតអញ្ជើញ លេខ ១០១៤ កប/អក/វក/លកអ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ទៅសហព័ន្ធសហជីពអំណាចកម្មករខ្មែរ, សហព័ន្ធសហជីពសេរីពលករខ្មែរ និងលោកលោកស្រី និងអ្នកតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ដែលជាភាគីកម្មករនិយោជិត (ភាគីដើមបណ្ដឹង) ដើម្បីមកចូលរួមសវនាការអាជ្ញាកណ្ដាល ដែលមានភ្ជាប់ជាមួយនូវព័ត៌មានច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ, ទីកន្លែងនៃសវនាការ និងលេខទូរស័ព្ទ/ទូរសារ សម្រាប់ទំនាក់ទំនងផងដែរ។

លោក សុខ សុខហួត ដែលជាហិរញ្ញិកសហព័ន្ធសហជីពអំណាចកម្មករខ្មែរ បានទទួលលិខិតអញ្ជើញនេះ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ០៨ និង ៤៤ នាទី ដោយបានចុះហត្ថលេខាបញ្ជាក់ការទទួលផងដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ភាគីកម្មករនិយោជិតពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឱ្យចូលរួមសវនាការអាជ្ញាកណ្ដាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

***<u>លក្ខខណ្ឌទី ០២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល</u>***

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា “ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល” នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ដែលបានលើកឡើងខាងលើនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្ដាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្ដាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្ដី

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ១១៥/០៦-អាកឃីដ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា *“ការដើរចេញពីបន្ទប់សវនាការមុនដំណើរការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចាប់ផ្ដើមអាចចាត់ទុកថា ជាការមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្ដាល ។”*

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ២៧/០៧-អ៊ឹម និង វេ ៣ *“ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបញ្ជាក់ថា មិនអាចដោះស្រាយវិវាទដទៃ ក្រៅពីវិវាទដែលមានបញ្ជាក់នៅក្នុងកំណត់ហេតុមិនសះជាបានទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងធ្វើការដោះស្រាយវិវាទ០៣ ចំណុចដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនសះជា ប៉ុណ្ណោះ ។ គ្រាន់តែ*

*ក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ជាក់មិនទាន់បញ្ចប់សព្វគ្រប់ សហព័ន្ធសហជីព សហជីពមូលដ្ឋាន និងតំណាងកម្មករនិយោជិតបានដើរចេញពីសវនាការ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទង្វើនេះ គឺជាការមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននោះក្នុងសវនាការ ។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ ពោលគឺភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន ។”*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានចូលរួមតែដំណាក់កាល (ក), (ខ), (គ) ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានចូលរួមដំណាក់កាល (ឃ) ឱ្យបានចប់សព្វគ្រប់ទេ ពីព្រោះ ភាគីកម្មករនិយោជិតចំនួន បានដើរចេញពីសវនាការ ដោយមិនបានជូនដំណឹងដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីនិយោកទេ ។ លើសពីនេះទៀត ភាគីកម្មករនិយោជិតមិនបានសុំការអនុញ្ញាតពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីនិយោជក ដើម្បីលើកពេលសវនាការដែរ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារនៃប្រការ ២១ ខាងលើនេះ ទេ ។ ដូចនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ។

***លក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន***

នៅក្នុងករណីនេះ ផ្អែកលើការបកស្រាយខាងលើ ភាគីកម្មករនិយោជិតបានដើរចេញពីសវនាការ ដោយមិនមានការជូនដំណឹងដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីនិយោជក និងមិនបានផ្តល់ហេតុផលអ្វីឡើយ ។ ដូច្នេះ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទាំងបីខាងលើ ត្រូវបានបំពេញ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ២០០/១៣-ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ២០០/១៣-ស៊ុន ខេង ហ្គាមេន (ខេមបូឌា) ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **យូ សួនធី**

ហត្ថលេខា ៖ ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា ៖ ------------------------------------